# PRESS RELEASE

## KOI CA ផ្តល់ថវិកា ១០ លានដុល្លារអាមេរិក ដើម្បីពង្រីកកិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីន និងផ្តល់ជំនួយដល់ជនរងគ្រោះនៅកម្ពុជាក្នុងឆ្នាំ ២០២១ និងឆ្នាំបន្តបន្ទាប់ទៀត

**រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១៖** ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានរួមគ្នា ជាមួយនឹងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងលើកំណត់ត្រានៃកិច្ចពិភាក្សាជាមួយនឹងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) សម្រាប់អនុវត្តគម្រោង *បោសសម្អាតមីនដើម្បីលទ្ធផលដំណាក់កាលទី ៤៖ សកម្មភាពបោសសម្អាតមីនដើម្បីការអភិវឌ្ឍមនុស្ស* (CfRIV)។

គម្រោង CfRIV រយៈពេល ៦ ឆ្នាំ អនុវត្តដោយអាជ្ញាធរមីន ជាមួយនឹងការគាំទ្រផ្នែកយុទ្ធសាស្ត្រ និងបច្ចេកទេសពី UNDP នេះផ្តោតលើការបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម បង្កើនការផ្តល់ជំនួយដល់ជនរងគ្រោះ និងការអប់រំគ្រោះថ្នាក់អំពីមីន ការពិនិត្យតាមដាននិងវាយតម្លៃ និងការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន។

រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ តាមរយៈ KOICA បានផ្តល់ថវិកា ១០ លានដុល្លារអាមេរិក ដល់វិស័យសកម្មភាពមីននៅកម្ពុជា តាមរយៈគម្រោង CfRIV នេះគិតចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៥។ គម្រោងនេះក៏ទទួលបានថវិកាគាំទ្រពីប្រទេសអូស្ត្រាលី នូវែលសេឡង់ UNDP និងរាជរដ្ឋាភិបាលកម្ពុជាផងដែរ។

វត្តមាននៃគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម បន្តនាំឱ្យមានការបាត់បង់អាយុជីវិត ការរងរបួស និងធ្វើឱ្យប្រជាពលរដ្ឋជាច្រើននាក់ ក្លាយជាជនមានពិការភាព នៅតាមតំបន់ជនបទនៅកម្ពុជា និងបានបង្កជាឧបសគ្គដ៏ធំមួយដល់ការពង្រីកការងារអភិវឌ្ឍន៍ផ្នែកកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ដោយយល់ច្បាស់ពីសារៈសំខាន់នៃផ្ទៃដីដែលមានសុវត្ថិភាពសម្រាប់ការអភិវឌ្ឍ កម្ពុជាបានអនុម័តគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ១៨ បន្ថែមមួយទៀត នោះគឺគោលដៅបញ្ចប់ផលប៉ះពាល់អវិជ្ជមាន បង្កឡើងដោយសារមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងបង្កើនការផ្តល់ជំនួយដល់ជនរងគ្រោះ។